**មាត្រា ៣១** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានក្របខ័ណ្ឌមន្ត្រីរាជការ និង មានខ្ទង់ចំណូល និង ចំណាយថវិការបស់ខ្លួន ។ ការគ្រប់គ្រងចំណូល និង ចំណាយថវិកា នៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅ ក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ ។

**ជំពូក ៤**

**អវសានបញ្ញត្តិ**

**មាត្រា ៣២** : រាល់អនុក្រឹត្យ និង សេចក្តីសំរេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង រាល់ក្រសួង និង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះមាស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

**អនុក្រឹត្យ លេខ ៥២ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មការពិនិត្យគ្រោងដេញថ្លៃលើសំណើ**

**« សាងសង់ធ្វើអាជីវកម្មប្រគល់វិញ »**

**( Build Operate Transfer : B.O.T)**

**របស់ក្រុមវិនិយោគនានាលើរោងចក្រដំណើរការយន្តហោះពោធិចិនតុង**

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

**ឡើង** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- យោងកិច្ចប្រជុំពិសេសរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៥ នាតំណាក់ សម្តេចក្រុមព្រះ ។
- ពិនិត្យលើភាពចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការពិនិត្យការដេញថ្លៃលើសំណើ«សាងសង់ធ្វើអាជីវកម្មប្រគល់វិញ» « Build Operate Transfer : B.O.T » របស់ក្រុមហ៊ុនវិនិយោគនានាលើព្រលានយន្តហោះពោធិចិនតុង ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ត្រាំ អ៊ីវទឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងជាអគ្គលេខាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម **ប៉ុក សំឯល** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាជ្ញាធរអាកាសចរស៊ីវិល | អនុប្រធាន |
| ៤-ឯកឧត្តម **ម៉ម សុផាណា** | អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា | អនុប្រធាន |
| ៥-ឯកឧត្តម **គៀវ ទ៊ាង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម **សុខ ចិន្តា** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧-ឯកឧត្តម **អ៊ិត ទិដឹត** | អគ្គលេខាធិការនៃគណៈកម្មការជាតិវិនិយោគទុន | សមាជិក |
| ៨-លោក **កៅ ម៉ុនហុង** | ទីប្រឹក្សាច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩-លោក **សៀង ឃាក់** | អគ្គនាយកក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |

www.pheakdeylaw.com

១០-លោក **អយ គឹមឈាង** ប្រធានការិយាល័យគ្រប់គ្រងទុន និងវិនិយោគទុនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១-លោក **យិត មុន្នីរ៉ា** អនុប្រធានមជ្ឈមណ្ឌលបច្ចេកទេសក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

១២-លោក **រស់ ម៉ូរ៉ាត** ស្ថាបត្យករនៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

**មាត្រា ២** : គណៈកម្មការនេះមានភារកិច្ចពិនិត្យ និង ជ្រើសរើសនូវក្រុមហ៊ុនវិនិយោគទុនសមស្របសំរាប់ព្រលានយន្តហោះពោធិចិនតុងលើរូបមន្ត « សាងសង់ធ្វើអាជីវកម្មប្រគល់វិញ ឬ **B.O.T** » ដើម្បីលើកជូនរាជរដ្ឋាភិបាលសំរេច ។

**មាត្រា ៣** : ក្រោយពីការជ្រើសរើសក្រុមហ៊ុនវិនិយោគទុនព្រលានយន្តហោះពោធិចិនតុងត្រូវបានសំរេចដោយរាជរដ្ឋាភិបាលហើយ គណៈកម្មការមានភារកិច្ចសិក្សារៀបរៀងកិច្ចសន្យា ( **Contract** )ដើម្បីបណ្ដោះនៅការអនុវត្តន៍ ។

**មាត្រា ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង និងស្ថាប័នពាក់ព័ន្ធ និងសាមីជនដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ : ៥៣ អនក្រ.បក**

**ស្ដីពីការប្រកាសទ្រព្យសម្បត្តិរដ្ឋ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

www.pheakdeylaw.com